**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**


**ក្រុមប្រឹក្សាអាជ្ញាកណ្តាល**

មជ្ឈមណ្ឌលភ្នំពេញ, អាគារ (A) , វិថី
សុធារស, សង្កាត់ទន្លេបាសាក់, ខណ្ឌចំការមន
ទូរស័ព្ទ/ទូរសារ : (៨៥៥-២៣)២២០ ៧៩៣


**លេខ និងឈ្មោះសំណុំរឿង : ៧៥/០៥ - ហ្វរធូន ហ្គាមេន**
**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៥**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល
## (ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក : **ម៉ារ សំបូរណា**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត : **អាន វីរៈ**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ : **គង់ ផល្លះ**

**ភាគីនៃវិវាទ**

១- **ភាគីនិយោជក**

ឈ្មោះ : **ក្រុមហ៊ុន ហ្វរធូន ហ្គាមេន និង វូលឡិន នីធីង ហ្វេកធើរី**

អាសយដ្ឋាន : ផ្លូវលេខ២១ ភូមិព្រៃកខ្សេវ ឃុំរកាខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល

ទូរស័ព្ទ : ០២៣ ៤២៥ ០២១ ០១២ ៨១៦ ៧២០ ទូរសារលេខ : ០២៣ ៤២៥ ០៣៥

**តំណាងភាគីនិយោជក :**

| | |
|---|---|
| ១-លោក សុខ ហាក់ | អនុប្រធានក្រុមហ៊ុន |
| ២-លោក លី លាង | ជំនួយការរដ្ឋបាលក្រុមហ៊ុន |
| ៣-លោក ឡុង ហ៊ាង | មន្ត្រី **GMAC** |

២- **ភាគីកម្មករនិយោជិត**

ឈ្មោះ : សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរប្រចាំក្រុមហ៊ុន ហ្វរធូន

អាសយដ្ឋាន : ផ្ទះលេខ ៦C ផ្លូវលេខ ៤៧៦ សង្កាត់ទួលទំពូង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ២៨២ ៦៥៣ ទូរសារលេខ : គ្មាន

តំណាងកម្មករនិយោជិត :

១-លោក អ៊ុំ វិសាល មន្ត្រីដោះស្រាយវិវាទ C.CAWDU

២-លោក លន់ ស៊ីម៉េត ប្រធានសហជីព C.CAWDU ប្រចាំក្រុមហ៊ុន ហ្វូរធ្យូន

៣-លោក យ៉ាន សារ៉ាន់ អនុប្រធានសហជីព C.CAWDU ប្រចាំក្រុមហ៊ុន ហ្វូរធ្យូន

៤-លោក ចន វ៉ាន់ថា លេខាសហជីព C.CAWDU ប្រចាំក្រុមហ៊ុន ហ្វូរធ្យូន

៥-លោក លី ឡាយ ទីប្រឹក្សាសហជីព C.CAWDU ប្រចាំក្រុមហ៊ុន ហ្វូរធ្យូន

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

យោងតាមកំណត់ហេតុក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា ចំណុចបញ្ហាមិនសះជាខាងក្រោមជាការទាមទាររបស់ភាគីកម្មករនិយោជិតនៃសំណុំរឿងវិវាទ:

១-កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួល៥០%ក្នុងពេលព្យួរការងារ និងរក្សាអត្ថប្រយោជន៍ផ្សេងៗនៅដដែល ។ ក្រុមហ៊ុនមិនឯកភាព គឺអាចផ្តល់ជូនបានប្រាក់សំរាប់ស្នាក់នៅចំនួន ១២ ដុល្លារ និងរក្សាប្រាក់រង្វាន់អតីតភាពការងារ ១០០% ក្នុងមួយខែតាមការឯកភាពគ្នាពីមុន រវាងក្រុមហ៊ុន និងប្រតិភូបុគ្គលិក ។

២-កម្មករទាមទារឱ្យផ្នែកវេចខ្ចប់ ឆ្កុះអំពូល ស៊ីឡូ ដូចផ្នែកផ្សេងៗ ។ ក្រុមហ៊ុនមិនឯកភាព ព្រោះការផ្តល់ប្រាក់ឈ្នួលទាក់ទិនលើផ្នែកបច្ចេកទេសនៃសង្វាក់ផលិតកម្ម ហើយប្រាក់ឈ្នួលដែលក្រុមហ៊ុនផ្តល់ជូនកន្លងមកត្រឹមត្រូវតាមច្បាប់ស្តីពីការងារហើយ ។

៣-កម្មករទាមទារឱ្យក្រុមហ៊ុនអនុវត្តការឈប់សំរាកប្រចាំឆ្នាំជូនកម្មករ គឺ ឆ្នាំទី៣ចំនួន១៩ថ្ងៃ ឆ្នាំទី៤ចំនួន១៩ថ្ងៃ ឆ្នាំទី៥ចំនួន១៩ថ្ងៃ និងឆ្នាំទី៦ ចំនួន២០ថ្ងៃឡើងទៅ ។ ក្រុមហ៊ុនមិនឯកភាព សុំអនុវត្តតាមការអនុវត្តកន្លងមក គឺ ឆ្នាំទី៣បន្ថែមជូន១ថ្ងៃ ឆ្នាំទី៤ ទី៥ (១៨ថ្ងៃក្នុង១ឆ្នាំ) ឆ្នាំទី៦ បន្ថែមជូន១ថ្ងៃ ។

៤-កម្មករទាមទារឱ្យក្រុមហ៊ុនទទួលយកលោក លី ឡាយ ចូលធ្វើការវិញ ។ ក្រុមហ៊ុនមិនឯកភាព ដោយសារសំណុំរឿងឈ្មោះ លី ឡាយ នេះត្រូវបានដោះស្រាយគ្នានៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល និងបញ្ជូនទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល ហើយក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបដិសេធការទាមទារនេះម្តងរួចមកហើយ ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ០៩៩ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាលដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ០៩៩ និង ប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ៥១៣ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៥ (អាណត្តិទីបី) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី ១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយ របាយការណ៍ស្តីអំពីការមិនសះជា លេខ ០០៣/០៥ ក.ប.វ/កណ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៥ ត្រូវបានបញ្ជូនមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៥ ។

## សវនាការ និង សង្ខេបនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ “A” វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៥ (វេលាម៉ោង១៣:០០ ដល់ម៉ោង១៦:០០ នាទី រសៀល)

**បញ្ហានៃនីតិវិធី :**

នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៥ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានធ្វើការផ្សះផ្សាវិវាទការងាររួមចំនួន១៤ចំណុច ហើយបានទទួលលទ្ធផលសះជាចំនួន១០ចំណុច និងមិនសះជាចំនួន០៤ចំណុច។ នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៥ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលសំណុំរឿង និងរបាយការណ៍ស្តីពីវិវាទការងារមិនសះជា លេខ ០០៣/០៥ ក.ប.វ /កណ របស់លោក **ធុល នាង** ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៥ ។

បន្ទាប់ពីបានទទួលសំណុំរឿងរួច ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីនិយោជក និងកម្មករនិយោជិតមកធ្វើការផ្សះផ្សា និងបើកសវនាការជំនុំជំរះលើករណីមិនសះជាចំនួន០៤ចំណុច ដែលនៅសល់ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៥ នៅវេលាម៉ោង ១៣:០០រសៀល ។ ភាគីទាំងពីរមានវត្តមានតាមការកោះអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។ នៅថ្ងៃផ្សះផ្សា និងបើកសវនាការនោះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមធ្វើការផ្សះផ្សាបន្ត ប៉ុន្តែមិនបានទទួលលទ្ធផលសះជាលើចំណុចណាមួយឡើយ ព្រោះភាគីកម្មករនិយោជិតមិនទាន់ធ្វើការសំរេចចិត្ត ហើយសន្យាថានឹងផ្តល់ចម្លើយមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅពេលក្រោយ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបើកសវនាការលើចំណុចមិនសះជាខាងលើ ។

នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៥ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានទទួលលិខិតពីសហជីព ដែលស្នើសុំដកការទាមទាររបស់ពួកគេវិញចំនួន៣ចំនុចគឺចំនុចទី១ ចំនុចទី២ និងចំណុចទី៤ ។ ហេតុដូច្នេះ នៅក្នុងសេចក្តីបង្គាប់ នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងធ្វើការពិចារណាតែលើចំណុចទី៣នៃបញ្ហា ដែលមិនសះជានោះទេ ដោយផ្អែកលើភស្តុតាងនិងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម :

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន

**ឯកសារ ឧត្ថុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក :

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុន ជូនលោក ឡុង ហ៊ាង ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៥

២- កំណត់ហេតុកិច្ចប្រជុំដោះស្រាយវិវាទរវាងប្រតិភូបុគ្គលិក និងតំណាងក្រុមហ៊ុន ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០៤

៣- សេចក្តីបង្គាប់របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលលើសំណុំរឿងលេខ ២០/០៥ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៥

៤- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០០៥

៥- លិខិតលេខ ០៤៨ ក.ប.វ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៥ របស់ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល ជមរាបមក នាយកក្រុមហ៊ុន ហ្វូរធ្យូន ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត

៦- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ហ្វូរធ្យូន ដែលអនុញ្ញាតដោយមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្តកណ្តាល ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៣ ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត :

១- លិខិតរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសំណើសុំដកនូវចំណុចសំណូមពរមួយចំនួនរបស់សហជីពកម្មករនៃរោងចក្រ ហ្វូរធ្យូន ដែលមានក្នុងសំណុំរឿងលេខ ៧៥/០៥ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ហ្វូរធ្យូន ហ្គាមេន លេខ ០០៣/០៥ ក.ប.វ /កណ របស់លោក **ធុល នាង** ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៥ ។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៥ ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ៣៩៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៥

២- លិខិតអញ្ជើញភាគីនិយោជក ចូលរួមសវនាការ លេខ៣៩៥ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០០៥ ។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យឯកសារផ្សេងៗដែលត្រូវបានដាក់ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល
- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និង ភាគីនិយោជក

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា :**

- នៅក្នុងក្រុមហ៊ុននេះបានអនុវត្តការឈប់សំរាកប្រចាំឆ្នាំដោយបន្ថែមការឈប់សំរាកមួយថ្ងៃនៅឆ្នាំទី៣ ផ្តល់ ១៩ថ្ងៃ ហើយនៅឆ្នាំទី៤ និងទី៥ ផ្តល់អោយ១៨ថ្ងៃ និង ឆ្នាំទី៦ ផ្តល់អោយ១៩ ឆ្នាំវិញ ។ ការអនុវត្តនេះផ្អែកលើការបកស្រាយមាត្រា ១៦៦ នៃច្បាប់ស្តីពីការងាររបស់ភាគីនិយោជក ។
- កម្មករនិយោជិតបានទាមទារអោយក្រុមហ៊ុនផ្តល់ការឈប់សំរាកប្រចាំឆ្នាំអោយពួកគេចំនួន ១៩ ថ្ងៃ នៅឆ្នាំទី៣ ទី៤ និងទី៥ ហើយចាប់ពីឆ្នាំទី៦ឡើងទៅសុំអោយក្រុមហ៊ុនផ្តល់២០ថ្ងៃ ដោយផ្អែកលើការបកស្រាយមាត្រា ១៦៦ នៃច្បាប់ស្តីពីការងាររបស់ភាគីកម្មករនិយោជិត ។

**ហេតុផលនៃសេចក្តីសំរេច**

ចំណុចបញ្ហានៅក្នុងសំណុំរឿងនេះ កើតឡើងដោយសារភាគីទាំងពីរមានការបកស្រាយខុសគ្នាអំពីមាត្រា ១៦៦ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការងារ ។

មាត្រា ១៦៦ នៃច្បាប់ស្តីពីការងារបានចែងថា " *លើកលែងតែមានបញ្ញត្តិក្នុងអនុញ្ញារួម ឬ កិច្ចសន្យាការងារវៀងខ្លួន ដែលផ្តល់អត្ថប្រយោជន៍ច្រើនជាងនេះ កម្មករនិយោជិតទាំងអស់ត្រូវមានសិទ្ធិឈប់សម្រាកប្រចាំឆ្នាំមានប្រាក់ឈ្នួលដែលនិយោជកត្រូវចេញឱ្យ ។ ឯថ្ងៃឈប់សម្រាកនោះត្រូវគិតជាថ្ងៃធ្វើការធម្មតាមួយថ្ងៃកន្លះក្នុងរយៈពេលធ្វើការមួយខែជាប់គ្នា .....*" ។ កថាខណ្ឌទី៤ នៃមាត្រា១៦៦ ចែងថា " *ថិរវេលានៃការឈប់សម្រាកដែលបានកម្រិតដូចខាងលើនេះ ត្រូវបន្ថែមឱ្យកម្មករនិយោជិតតាមអតីតភាពរបស់ខ្លួនក្នុងសហគ្រាសដោយត្រូវបន្ថែមមួយថ្ងៃ "ធ្វើការ "ក្នុងរយៈពេលធ្វើការបានបីឆ្នាំ...*" ។

ភាគីនិយោជកបានអះអាងថា ក្រុមហ៊ុនបានអនុវត្តតាមមាត្រា ១៦៦ នៃច្បាប់ស្តីពីការងារហើយ ពីព្រោះក្រុមហ៊ុនបានផ្តល់ការឈប់សម្រាកប្រចាំឆ្នាំ ដោយបន្ថែមការឈប់សំរាកមួយថ្ងៃនៅឆ្នាំទី៣ គឺផ្តល់១៩ថ្ងៃ ហើយនៅឆ្នាំទី៤ និងទី៥ ផ្តល់អោយ១៨ថ្ងៃ និង ឆ្នាំទី៦ ផ្តល់អោយ១៩ ឆ្នាំវិញ ។

ភាគីកម្មករនិយោជិតពុំឯកភាពលើការយល់ឃើញលើមាត្រា១៦៦នៃច្បាប់ស្តីពីការងារ និងការអនុវត្តខាងលើរបស់និយោជកទេ ហើយបានទាមទារអោយក្រុមហ៊ុនផ្តល់ការឈប់សំរាកប្រចាំឆ្នាំអោយពួកគេចំនួន ១៩ថ្ងៃ នៅឆ្នាំទី៣ ទី៤ និងទី៥ ហើយចាប់ពីឆ្នាំទី៦ឡើងទៅសុំអោយក្រុមហ៊ុនផ្តល់២០ថ្ងៃ ។ តារាងខាងក្រោមនេះបញ្ជាក់ពីការយល់ឃើញរបស់ភាគីទាំងពីរ :

| ចំនួនឆ្នាំធ្វើការ | ការអះអាងរបស់កម្មករនិយោជិត | ការអះអាងរបស់និយោជក |
|---|---|---|
| ឆ្នាំទី១ | ១៨ថ្ងៃ | ១៨ថ្ងៃ |
| ឆ្នាំទី២ | ១៨ថ្ងៃ | ១៨ថ្ងៃ |
| ឆ្នាំទី៣ | ១៩ថ្ងៃ | ១៩ថ្ងៃ |
| ឆ្នាំទី៤ | ១៩ថ្ងៃ | ១៨ថ្ងៃ |
| ឆ្នាំទី៥ | ១៩ថ្ងៃ | ១៨ថ្ងៃ |
| ឆ្នាំទី៦ | ២០ថ្ងៃ | ១៩ថ្ងៃ |
| ឆ្នាំទី៧ | ២០ថ្ងៃ | ១៨ថ្ងៃ |
| ឆ្នាំទី៨ | ២០ថ្ងៃ | ១៨ថ្ងៃ |
| ឆ្នាំទី៩ | ២០ថ្ងៃ | ១៩ថ្ងៃ |

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ពាក្យពេចន៍នៃមាត្រា ១៦៦ ត្រង់វាក្យខ័ណ្ឌទី ៤ ដែលថា "*ត្រូវបន្ថែមមួយថ្ងៃធ្វើការក្នុងរយៈពេលធ្វើការបានបីឆ្នាំ* " ពុំមានលក្ខណៈច្បាស់លាស់ ហើយត្រូវបានគេយកមកបកស្រាយខុសៗគ្នា ដោយសារតែមានការយល់ឃើញខុសៗគ្នា ។ ហេតុដូច្នេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពន្យល់ដោយផ្អែកលើគោលការណ៍ច្បាប់ គោលការណ៍សមធម៌ និងគោលបំណងនៃច្បាប់ការងារ ដូចខាងក្រោម :

១- <u>គោលការណ៍ច្បាប់</u>

ជាគោលការណ៍ច្បាប់ នៅពេលដែលពាក្យពេចន៍នៃបទបញ្ញត្តិណាមួយរបស់ច្បាប់មានលក្ខណៈមិនច្បាស់លាស់នោះ គេត្រូវធ្វើការបកស្រាយបញ្ញត្តិច្បាប់នោះ ដោយផ្អែកទៅលើគោលបំណងនៃច្បាប់ និងភាពស៊ីសង្វាក់គ្នារវាងបញ្ញត្តិដែលពុំច្បាស់លាស់ និងបញ្ញត្តិដទៃទៀតនៃច្បាប់នោះ ។ នៅក្នុងន័យនៃមាត្រា ១៦៦ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ថា ការបន្ថែមចំនួនថ្ងៃឈប់សម្រាកប្រចាំឆ្នាំ គឺ ពឹងផ្អែកទៅលើការកើនឡើងនៃអតីតភាពការងាររបស់កម្មករនិយោជិតនៅក្នុងរោងចក្រ ឬសហគ្រាសណាមួយ ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់

ឃើញថា គួរបកស្រាយពាក្យ" **អតីតភាព** " នៃការងារដែលមានលក្ខណៈស្របគ្នាទៅនឹងគំនិត ដែលប្រើនៅក្នុងមាត្រាដទៃទៀតនៃច្បាប់នេះ។

គំនិតអតីតភាពនៃការងារនៅក្នុងមាត្រាដទៃទៀតនៃច្បាប់ស្តីពីការងារ ឧទាហរណ៍ មាត្រា៧៣ មាត្រា៧៥ មាត្រា៨៩ និង មាត្រា៩៥ គឺជាគំនិតដែលមានគោលបំណងថា ការបំរើការងាររបស់កម្មករនិយោជិតដែលផ្តល់ទៅឱ្យសហគ្រាសមួយមានថិរវេលាកាន់តែច្រើន កម្មករនិយោជិតនោះនឹងទទួលបានសិទ្ធិ និង បុព្វសិទ្ធិកាន់តែច្រើនទៅតាមនោះដែរ ។ ឧទាហរណ៍ មាត្រា៧៣ និង៧៥ នៃច្បាប់ស្តីពីការងារ កំណត់ពីការកើនឡើងនៃរយៈពេលនៃការជូនដំណឹងសំរាប់ការបញ្ចប់កិច្ចសន្យាការងារ ដោយយោងទៅលើរយៈពេលនៃកិច្ចសន្យា ឬ រយៈពេលដែលកម្មករនិយោជិតបានបំពេញការងារឱ្យនិយោជកនោះ ។ យោងតាមមាត្រា៧៥ កម្មករនិយោជិតដែលធ្វើការជាប់ក្នុងសហគ្រាសបានពី ៦ ខែ ទៅ ២ ឆ្នាំ គេមានសិទ្ធិទទួលបានការជូនដំណឹងមុនជាអប្បបរមាចំនួន ១៥ ថ្ងៃ ។ បើគេធ្វើការបានពី ៥ ឆ្នាំ ទៅដល់ ១០ ឆ្នាំ នោះរយៈពេលនៃការជូនដំណឹងកើនឡើងដល់ទៅ ២ ខែ ។ បើគេពិនិត្យលើការកើនឡើងនោះ យើងឃើញថា សិទ្ធិដែលកម្មករនិយោជិតទទួលបានត្រូវកើនឡើងទៅតាមដំណាក់កាលនៃពេលវេលាដែលកំណត់ទុក ។ បើទោះជាកិច្ចសន្យាត្រូវបញ្ចប់នៅឆ្នាំណាមួយក៏ដោយនៃចន្លោះពីឆ្នាំទី ៥ និងឆ្នាំទី ១០ កម្មករនិយោជិតត្រូវទទួលបានការជូនដំណឹងរយៈពេលយ៉ាងតិច ២ ខែ ។ មានន័យថា សិទ្ធិដែលកម្មករនិយោជិតទទួលបានក្នុងដំណាក់កាល និង ចន្លោះពេលនីមួយៗនោះ មិនអាចត្រូវបានកាត់បន្ថយវិញទេ ។ ដូចគ្នាដែរ មាត្រា៨៩ នៃច្បាប់ស្តីពីការងារកំណត់ពីការកើនឡើងនៃប្រាក់បំណាច់បណ្តេញចេញពីការងារ ដោយយោងទៅតាមថិរវេលានៃការងាររបស់កម្មករនិយោជិត ។ កម្មករនិយោជិតដែលបំពេញការងារបានពី ៦ ខែ ទៅ ១ ឆ្នាំ ត្រូវទទួលប្រាក់បំណាច់ស្មើនឹង៧ថ្ងៃនៃប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំ ។ ចំនួនប្រាក់បំណាច់នោះ ត្រូវកើនឡើងដល់ ១៥ ថ្ងៃ ប្រសិនបើកម្មករនិយោជិតបំពេញការងារបានលើសពី ១ ឆ្នាំ ។ សិទ្ធិនៃការទទួលបានប្រាក់បំណាច់បណ្តេញចេញកើនឡើងជានិរន្ត និងជាសិទ្ធិដែលកម្មករនិយោជិតត្រូវទទួលបានជាស្វ័យប្រវត្តិ យោងតាមថិរវេលាបំរើការងារឱ្យនិយោជក ហើយសិទ្ធិនេះពុំអាចកាត់បន្ថយមកវិញបានទេ ។ ឧទាហរណ៍មួយទៀត គឺ មាត្រា៩៥ នៃច្បាប់ស្តីពីការងារនេះ ចែងពីការបញ្ឈប់ពីការងាររួមគ្នា សហគ្រាសត្រូវពិចារណាលើអតីតភាពនៃការងាររបស់កម្មករនិយោជិត គឺថា កម្មករនិយោជិតដែលមានអតីតភាពការងារតិចត្រូវបានបញ្ឈប់មុន ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា អតីតភាពការងារ គឺជារយៈពេលនៃការធ្វើការងារជាបន្តបន្ទាប់ ដែលផ្តល់សិទ្ធិ ឬ បុព្វសិទ្ធិបន្ថែមទៅឱ្យកម្មករនិយោជិត ដោយផ្អែកទៅលើថិរវេលាបំរើការងារជាបន្តបន្ទាប់ទៅឱ្យនិយោជក ។ ជាទូទៅ កម្មករនិយោជិតដែលមានអតីតភាពច្រើនអាចទទួលបានផលប្រយោជន៍ច្រើនជាងកម្មករនិយោជិតដែលមានអតីតភាពការងារតិចជាង ដូចជាផលប្រយោជន៍ពាក់ព័ន្ធនឹងការផ្លាស់ប្តូរការងារ ការតម្លើងឋានៈ ការជូនដំណឹងពីការបញ្ចប់កិច្ចសន្យាការងារ ការឈប់សម្រាកប្រចាំឆ្នាំ និង អាទិភាពក្នុងការទទួលបានការងារធ្វើឡើងវិញ ។ល។ សិទ្ធិ និង ផលប្រយោជន៍ ដែលកម្មករនិយោជិតទទួលបានពីអតីតភាពការងារនេះ

ពុំអាស្រ័យលើផលិតភាព ឬ ការកើនឡើងនៃប្រាក់ចំណូលរបស់និយោជកទេ ដូចជាករណីប្រាក់បុព្វលាភ ឬ ប្រាក់រង្វាន់នោះទេ **ប៉ុន្តែវាជាសិទ្ធិដែលកម្មករនិយោជិតទទួលបានតាមច្បាប់ជាស្វ័យប្រវត្តិ** ដោយផ្អែកទៅលើ ចិរវេលាដែលខ្លួនបានបំពេញការងារឱ្យនិយោជក ។ សិទ្ធិនេះមិនអាចត្រូវបានកាត់បន្ថយ ឬ កែប្រែតាមស្ថានភាព ឬ ដោយឆន្ទៈរបស់និយោជក ឬ ដោយការព្រមព្រៀងណាមួយ ឬ ដោយភ្ជាប់ជាមួយលក្ខខណ្ឌណាផ្សេងទៀតនោះទេ លើកលែងតែការកែប្រែនោះផ្តល់ប្រយោជន៍ឱ្យកម្មករនិយោជិតច្រើនជាងផលប្រយោជន៍ដែលច្បាប់បានកំណត់ ។ អតីតភាពនោះ នឹងឈប់បន្ត នៅពេលដែលកម្មករនិយោជិតឈប់ធ្វើការងារឱ្យសហគ្រាសនោះប៉ុណ្ណោះ ។

## ២- <u>គោលការណ៍សមធម៌</u>

គោលការណ៍សមធម៌ក៏គាំទ្រគំនិតអតីតភាពនេះផងដែរ ។ តាមការសិក្សាផ្នែកសេដ្ឋកិច្ចក៏បញ្ជាក់ផងដែរថា ការយល់ដឹងពីការងារជំនាញ និង ភាពថ្មីករបស់កម្មករនិយោជិតកើនឡើងស្របទៅតាមរយៈពេលដែលកម្មករនិយោជិតនោះបានបំពេញការងារឱ្យនិយោជក ។ ចិរវេលាការងាររបស់កម្មកនិយោជិតកាន់តែច្រើន កម្មករនិយោជិតនោះកាន់តែអាចធ្វើការងារកាន់តែល្អឡើង និង កាន់តែលឿនឡើង ចំណែកនិយោជកក៏ទទួលបាននូវផលប្រយោជន៍កាន់តែច្រើន ដោយសារផលិតផលកាន់តែកើនឡើង និងប្រសិទ្ធភាពការងារកាន់តែល្អឡើងផងដែរ ។ ហេតុនេះ វាជាការសមហេតុផលណាស់ ដែលនិយោជកផ្តល់ផលប្រយោជន៍ និង ការលើកទឹកចិត្តមួយចំនួនដល់កម្មករនិយោជិត ដែលបានបំពេញការងារនៅក្នុងសហគ្រាសរបស់ខ្លួនកាន់តែយូរនោះ ហើយផលប្រយោជន៍ ដែលផ្តល់ឱ្យពួកគេ ក៏គួរតែត្រូវបានបន្ថែមជាដរាបនៅពេលដែលការយល់ដឹង ជំនាញ និង ភាពថ្មីក ក្នុងការងាររបស់កម្មករនិយោជិតនោះកាន់តែកើនឡើងដែរ ។ ដូច្នេះ តាមគោលការណ៍សមធម៌ កម្មករនិយោជិតគួរតែមានសិទ្ធិទទួលបានថ្ងៃឈប់សម្រាកកើនឡើង ហើយការកើនឡើងនោះពុំគួរអាចធ្លាក់ចុះវិញទេ ដរាបណាអតីតភាពការងាររបស់ខ្លួននៅតែកើនឡើងនោះ ។

## ៣- <u>គោលបំណងនៃច្បាប់ស្តីពីការងារ</u>

បន្ថែមពីលើនេះទៀត *គោលបំណងនៃច្បាប់ការងារនេះ គឺធ្វើឡើង ដើម្បីផលប្រយោជន៍របស់កម្មករនិយោជិតផង និងនិយោជកផង* ។ ហេតុនេះហើយខ្លឹមសានៃមាត្រា ១៦៦ ត្រង់វាក្យខណ្ឌទី ៤ ដែលថា "*ត្រូវបន្ថែមមួយថ្ងៃធ្វើការ ក្នុងរយៈពេលធ្វើការបានបីឆ្នាំ*" នេះ គឺមានបំណងលើកទឹកចិត្តឱ្យកម្មករខិតខំធ្វើការ ហើយមានទឹកចិត្តចង់បន្តធ្វើការឱ្យនិយោជករបស់ខ្លួនបានយូរ ពីព្រោះនៅពេលកម្មករធ្វើការឱ្យនិយោជកកាន់តែយូរនោះ ពួកគេនឹងមានអត្ថប្រយោជន៍បន្ថែមកាន់តែច្រើន គឺបានឈប់សំរាកប្រចាំឆ្នាំច្រើនថ្ងៃជាងកម្មករ ដែលមានអតីតភាពតិចឆ្នាំជាង ។ បើគេរត់ចោលនិយោជក ហើយទៅរកនិយោជកថ្មីនោះ ពួកគេនឹងបាត់បង់ផលប្រយោជន៍នេះ ។ រីឯនិយោជកបានផលប្រយោជន៍ដូចគ្នាពីកម្មករដែលធ្វើការយូរ **គឺទីមួយ** បទពិសោធការងារ

និងធ្វើការបានលឿន **ទីពីរ** សេចក្តីស្មោះត្រង់ និងការចង់បន្តការងារបានយូរថែមទៀត **និងទីបី** ការយល់គ្នារវាងនិយោជក និងកម្មករនិយោជិត ។

ដោយផ្អែកទៅលើគោលការណ៍ច្បាប់ គោលការណ៍សមធម៌ និងគោលបំណងនៃច្បាប់ការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា យោងតាមមាត្រា ១៦៦ នៃច្បាប់ស្តីពីការងារ កម្មករនិយោជិត ដែលធ្វើការបាន៣ឆ្នាំ ពួកគេមានសិទ្ធិទទួលការឈប់សំរាក១៩ថ្ងៃនៅឆ្នាំទី៤ ទី៥ និងទី៦ ហើយនៅពេលធ្វើការបាន៣ឆ្នាំបន្ថែមទៀត ពួកគេនឹងមានសិទ្ធិឈប់សំរាកប្រចាំឆ្នាំចំនួន ២០ថ្ងៃ នៅឆ្នាំទី៧ ទី៨ និងទី៩ ព្រមទាំងនឹងត្រូវធ្វើដូច្នេះជាបន្តបន្ទាប់ទៀតនៅរៀងរាល់បីឆ្នាំម្តង ។

| ចំនួនឆ្នាំធ្វើការ | ការឈប់សំរាកប្រចាំឆ្នាំតាមមាត្រា ១៦៦ កថាខណ្ឌទី ៤ |
|---|---|
| ឆ្នាំទី១ | ១៨ថ្ងៃ |
| ឆ្នាំទី២ | ១៨ថ្ងៃ |
| ឆ្នាំទី៣ | ១៨ថ្ងៃ |
| ឆ្នាំទី៤ | ១៩ថ្ងៃ |
| ឆ្នាំទី៥ | ១៩ថ្ងៃ |
| ឆ្នាំទី៦ | ១៩ថ្ងៃ |
| ឆ្នាំទី៧ | ២០ថ្ងៃ |
| ឆ្នាំទី៨ | ២០ថ្ងៃ |
| ឆ្នាំទី៩ | ២០ថ្ងៃ |
| ឆ្នាំទី១០ | ២១ថ្ងៃ |
| ឆ្នាំទី១១ | ២១ថ្ងៃ |
| ឆ្នាំទី១២ | ២១ថ្ងៃ |

តារាងខាងលើជាការបកស្រាយដោយផ្អែកតាមមាត្រា ១៦៦ កថាខណ្ឌទី ៤ នៃច្បាប់ស្តីពីការងារ និងសេចក្តីសំរេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងលេខ៥១/០៤-សាំហាន់ សំណុំរឿងលេខ៦២/០៤-អ៊ីស៊ីន និង សំណុំរឿងលេខ៦៨/០៥-ហ្គោលីដា ។

យោងតាមការបង្ហាញពីអង្គហេតុ អង្គច្បាប់ និង ហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសំរេច :

**បង្គាប់**

ក្រុមហ៊ុនត្រូវផ្តល់ការឈប់សំរាកប្រចាំឆ្នាំឱ្យកម្មករនិយោជិតតាមអតីតភាពរបស់ខ្លួនក្នុងសហគ្រាសដោយត្រូវបន្ថែមមួយថ្ងៃ "ថ្ងៃធ្វើការ" ក្នុងរយៈពេលធ្វើការបានបីឆ្នាំ.គឺ ផ្តល់ថ្ងៃឈប់សម្រាកប្រចាំឆ្នាំមានប្រាក់ឈ្នួល ចំនួន១៩ថ្ងៃសំរាប់ឆ្នាំទី ៤ ឆ្នាំទី ៥ និងឆ្នាំទី ៦ និងផ្តល់ថ្ងៃឈប់សម្រាកប្រចាំឆ្នាំមានប្រាក់ឈ្នួលចំនួន ២០ ថ្ងៃនៅឆ្នាំទី៧ ឆ្នាំទី៨ និងឆ្នាំទី៩.... ព្រមទាំងធ្វើដូច្នេះជាបន្តបន្ទាប់ទៀតនៅរៀងរាល់៣ឆ្នាំម្តង ។

ប្រភេទនៃសេចក្តីបង្គាប់ : សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច

*សេចក្តីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ចំនួន០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **ម៉ារ សំបូរណា**

ហត្ថលេខា: -----------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **អាន ទីរៈ**

ហត្ថលេខា: -----------------------------

ប្រធានក្រុមអាជ្ញាកណ្តាល :

ឈ្មោះ : **គង់ ផល្លះ**

ហត្ថលេខា: -----------------------------